archive.today
webpage capture

Saved from https://www.vodkhmer.news/2020/06/07/almost-hotels-former-employees-pa search
no other snapshots from this url

Redirected from https://vodkhmer.news/2020/06/07/almost-hotels-former-employees-paid-exc
no other snapshots from this url

All snapshots from host vodkhmer.news
from host www.vodkhmer.news

24 Apr 2024 03:51:12 UTC

Webpage Screenshot share download .zip report bug or abuse



# អតីតបុគ្គលិក Great Duke ស្ទើរទាំងអស់ទទួលបានការទូទាត់សំណង ខណៈនៅសល់តែម្នាក់ជាជនបរទេស

ព័ត៌មានជាតិ ការងារ

លោក ណាត សុភាព | ០៧ មិថុនា ២០២០
ម៉ោង ១២:១៥




សហជីពតំណាងឲ្យអតីតបុគ្គលិកសណ្ឋាគារ The Great Duke អះអាងថា រដ្ឋាភិបាលបានទូទាត់ប្រាប់អតីតភាពការងារជូនអតីតបុគ្គលចំនួន ១៥១នាក់ហើយ ប៉ុន្តែ នៅសល់ម្នាក់ទៀតដែលជាជនបរទេសមិនទាន់មកបើកលុយនៅឡើយដោយសារបញ្ហាវិបត្តិកូវីដ១៩។

ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជាប្រចាំនៅសណ្ឋាគារ The Great Duke លោក ទូច កុសល បានប្រាប់វីអូឌីនៅថ្ងៃនេះថា ក្រសួងការងារបានបើកប្រាក់អតីតភាពជូនអតីតបុគ្គលិកសណ្ឋាគារ The Great Duke បានចំនួន ១៥១នាក់។

ប៉ុន្តែ លោក កុសល ប្រាប់ថា នៅសល់ជនជាតិឥណ្ឌូនេស៊ីម្នាក់ដែលធ្វើការផ្នែកចុងភៅ មិនទាន់បានទៅបើកប្រាក់អតីតភាពការងារប្រហែលជិត ៤ពាន់ដុល្លារនៅឡើយ ដោយសារពិបាកធ្វើដំណើរត្រឡប់មកម្ពុជា ខណៈកូវីដ១៩ ត្រូវចំណាយលុយលើការពិនិត្យសុខភាព ពេលវេលា រួមទាំងបញ្ហាផ្សេងទៀតជាដើម។

លោក ទូច កុសល ប្រាប់ថា៖ «គាត់ប្រាប់ថា គាត់ទៅ[ត្រឡប់មកកម្ពុជា]មិនទាន់បានទេ ដោយសារគេត្រូវការពិនិត្យសុខភាព ចំណាយផ្សេងៗ

ច្រើន។ អ៊ីចឹងគាត់ថា ចាំជំងឺកូវីដ១៩ប្រសើរឡើងវិញបានគេមកវិញបាន»។

ទោះជាយ៉ាងណា លោក កុសល អះអាងថា ជនជាតិតណ្ហូនេស៊ីរូបនោះបានប្រាប់គាត់ថា នៅពេលដែលស្ថានភាពជំងឺកូវីដ១៩ ធូរស្រាលឡើងវិញ ជនជាតិរូបនោះនឹងធ្វើដំណើរមកកម្ពុជា ដើម្បីបើកប្រាក់អតីតភាពផងដែរ។

ប្រភពដដែលបញ្ជាក់ថា ក្រសួងការងារទុករយៈពេល ៣ឆ្នាំ ដើម្បីឲ្យអតីតបុគ្គលិកសណ្ឋាគារ The Great Duke ទៅបើកប្រាក់អតីតភាពការងារនោះ។

កាលពីថ្ងៃទី២០ ខែកុម្ភៈ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានចេញសេចក្ដីសម្រេចតម្រូវឱ្យថៅកែសណ្ឋាគារទូទាត់ប្រាក់សំណងចំនួន ៣ចំណុច ទៅតាមការទាមទាររបស់អតីតបុគ្គលិកសណ្ឋាគារនេះ។ ក្រោយមកម្ចាស់សណ្ឋាគារមិនព្រមទូទាត់ឲ្យនោះទេ រហូតដល់ថ្ងៃទី២១ ខែឧសភា សហព័ន្ធសហជីព និងអតីតបុគ្គលិកជិត ១០០នាក់នាំគ្នាតវ៉ានៅមុខសណ្ឋាគារជាថ្មីទៀត។ នៅពេលនោះ អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បានចេញមុខសន្យាដោះស្រាយជូនពួកគេកាលពីចុងសប្ដាហ៍មុន។

សណ្ឋាគារលំដាប់ផ្កាយ៥ ដឹហ្គ្រេតឌ្យុកភ្នំពេញ (The Great Duke Phnom Penh) គឺជាអតីតសណ្ឋាគារអាំងទែកុងទីណង់តាល់ (InterContinental) មានទីតាំងនៅកណ្ដាលរាជធានីភ្នំពេញ ប្រកាសបិទទ្វារចាប់ពីចុងខែធ្នូឆ្នាំមុន បន្ទាប់ពីប្រតិបត្តិការអាជីវកម្មរបស់ខ្លួនអស់រយៈពេល ២៣ឆ្នាំ។ ចំណែកប្រាក់អតីតភាពការងារដែលត្រូវទូទាត់ជូនអតីតបុគ្គលិក ១៥២នាក់នោះ សរុបចំនួន ៣២ម៉ឺនដុល្លារ៕

សិទ្ធិការងារ

---

**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង



វិវាទការងារនៅរោងចក្រចំនួន៤ មិនទាន់ដោះស្រាយចប់ ខណៈកម្មករដាក់បណ្ដឹងទៅក្រសួងការងារជាច្រើនខែ

១៦ ធ្នូ ២០២២ ម៉ោង ១៦:៤៨



អាជ្ញាធរមូលដ្ឋាននៅក្រុងប៉ោយប៉ែត ហាមសមាគមមួយដែលធ្វើការផ្នែកសិទ្ធិការងារមិនឱ្យលើកស្លាក

២៤ វិច្ឆិកា ២០២២ ម៉ោង ១៦:២៨



សហគមន៍ចម្រុះវិស័យទាមទារឱ្យរដ្ឋាភិបាលដោះស្រាយវិបត្តិដីធ្លី នយោបាយ សិទ្ធិមនុស្ស និងការងារ

៣ វិច្ឆិកា ២០២២ ម៉ោង ២១:៣១

---

### សូមផ្ដល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចេញមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

| ព័ត៌មានថ្មីៗ | បោះឆ្នោត |
| --- | --- |




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រីរឿងផ្ដល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល

១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤



ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ

១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣




អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង

១១ កុម្ភៈ ២០២៣ ម៉ោង ១៥:៤៦



ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ មាណ្ណារ៉ា ជាទីប្រឹក្សាលោក ហ៊ុន សែន

១១ កុម្ភៈ ២០២៣ ម៉ោង ១៤:៥៣






VOD

VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្ដល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។



info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៨A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ




- ស្វែងរកព័ត៌មាន
- ព័ត៌មានជាសំឡេង
- VOD ENGLISH
- ទិន្នន័យចាស់ៗ
- អំពីយើង
- ក្រមសីលធម៌
- ទំនាក់ទំនង
- ឱកាសការងារ
- បណ្ណាសាររូបភាព
- ទូរទស្សន៍

© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម